ភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១

# អនុក្រឹត្យលេខ ១១ អនក្រ
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរ
# អាកាសចរ ស៊ីវិលកម្ពុជា
# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅ កម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣
- យោងតាមការចាំបាច់

## សំរេច

**មាត្រា ១ :** អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ជាភាសាបារាំងហៅថា **Autorité de l'Aviation Ci du Cambodge** សរសេរកាត់ " **A.A.C.C** " បានបង្កើតឡើងក្នុងគោលបំណងរៀបចំ វិញ នូវគ្រប់សកម្មភាព នៃអាកាសចរស៊ីវិល ដែលមានកន្លងមកនិងឈានទៅអនុវត្តនយោបាយ សេរី ូបនីយ កម្មផ្នែកអាកាសចរដោយផ្អែកលើមូលដ្ឋាន នៃការប្រកួតប្រជែង និងមានប្រសិទ្ធភាព ។ នយោបាយសេរីភាវូបនីយកម្មនេះ គឺជាមូលដ្ឋានសំរាប់អនុញ្ញាតអោយផ្នែកអាកាសចរស៊ីវិល បើកទ្វារចំហចំពោះសកលលោកទាំងមូល ព្រមទាំងឆ្លើយតបបានទៅនឹងកំណើននៃចរាចរផ្លូវអាកាស និងចំនួនអ្នកធ្វើដំ កាន់តែច្រើនឡើង ។

ការដាក់ផ្នែកនេះអោយមានសេវាកម្មដ៏ត្រឹមត្រូវលើផ្នែកបច្ចេកទេស ប្រកបដោយប្រសិទ្ធភាព គឺ ចាំបាច់ដាច់ខាត សំដៅទាក់ទាញក្រុមហ៊ុន អាកាសចរជាច្រើនអោយចូលមកកម្ពុជា ។

**មាត្រា ២ :** អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

- អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

- អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ដឹកនាំដោយប្រធានមួយរូបមានឋានៈជាអនុរដ្ឋលេខាធិការ សមាជិកមួយចំនួនទៀត ដែលត្រូវតែងតាំងឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ។

- ប្រធានអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា មានអគ្គនាយកមួយរូបព្រមទាំងអគ្គនាយករង ពីររូបទៀត ជាជំនួយការ ។

- អគ្គនាយករងមួយរូបទទួលបន្ទុកកិច្ចការអាកាសចរស៊ីវិល និងអគ្គនាយករងមួយរូបទៀត ទទួលបន្ទុកកិច្ចការគ្រប់គ្រង និងកិច្ចការរដ្ឋបាលនៃអាកាសយានដ្ឋាន ។

- អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ត្រូវមានគណៈកម្មការមួយទទួលបន្ទុកការងារវិនិយោគ និងអភិបាលហិរញ្ញវត្ថុមួយរូប ។

**មាត្រា ៣ :** មុខងាររបស់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាមានដូចតទៅ ÷

អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ត្រូវខិតខំយកចិត្តទុកដាក់អោយបានល្អប្រសើរទៅលើគ្រប់ផ្នែក ក្នុងការងារអាកាសចរស៊ីវិល តាំងពីការត្រួតពិនិត្យលើចរាចរហោះហើរ រហូតដល់ការគ្រប់គ្រងអាកាសយានដ្ឋាន នៅទូទាំងប្រទេស ។

- ដឹកនាំនិងត្រួតពិនិត្យអាជ្ញាធរអាកាសយានដ្ឋានទូទាំងប្រទេស ។

- ដឹកនាំគ្រប់គ្រងអាជ្ញាធរ នៃអគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ។

- បង្កើតបណ្តាសេវាកម្មលើការងារត្រួតពិនិត្យចរាចរហោះហើរ ។

- ផ្តល់ឬសំរបសំរួលកិច្ចប្រតិបត្តិការរុករក និងជួយសង្គ្រោះយន្តហោះ ដែលមានគ្រោះអាសន្ន ។

- ផ្តល់ជំនួយចាំបាច់ អោយអាជ្ញាធរអាកាសយានដ្ឋាន ដើម្បីបង្ការនិងពន្លត់អគ្គីភ័យ ។

- ជួយអភិវឌ្ឍន៍ដល់ការងារដឹកជញ្ជូនតាមផ្លូវអាកាស ដោយកំណត់អោយមានបទបញ្ញត្តិ និងវិធានការដើម្បីជំរុញដំណើរការទៅមុខ នៃអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ។

- ជូនយោបល់រាជរដ្ឋាភិបាលកម្ពុជា អំពីកិច្ចការអាកាសចរស៊ីវិល ។

- ធ្វើសកម្មភាពនៅលើឆាកអន្តរជាតិ ក្នុងនាមជាតំណាងអាជ្ញាធរជាតិ លើវិស័យអាកាសចរស៊ីវិល ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានន័យ ផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ ៖** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួងដែលពាក់ព័ន្ធ និងប្រធាន អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា មានភារកិច្ចអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

## ជ. រាជរដ្ឋាភិបាល

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

[illegible]